ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ២១៤
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤
សាលក្រមរដ្ឋប្បវេណីលេខៈ០២១/គ
ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តកណ្តាល**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ២១៤ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល។

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល។

**-ដើមចោទ៖** ឈ្មោះ [redacted] សុគីម ភេទស្រី កើតឆ្នាំ១៩៩៤ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted]

-អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖ លោកស្រីមេធាវី [redacted] អត្តលេខៈ ១១២៤ និងលោកស្រីមេធាវី [redacted] អត្តលខៈ ២៧២៦T មានការិយាល័យមេធាវី [redacted] មានអាសយដ្ឋានស្ថិតនៅអគារលេខៈ [redacted]

**-ចុងចម្លើយ៖** ឈ្មោះ [redacted] ឫទ្ធី ភេទប្រុស កើតឆ្នាំ១៩៩៥ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]

**អង្គហេតុ និង ចំណុចវិវាទ**

**១-ការទាមទាររបស់ដើមចោទ**

ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ៖

១.១-ឱ្យឈ្មោះ [redacted] សុគីម បានលែងលះជាមួយឈ្មោះ [redacted] ឫទ្ធី ។

១.២-បង្គាប់ឱ្យឈ្មោះ [redacted] ឫទ្ធី ប្រគល់ផ្ទះល្វែងលេខC5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ទៅឱ្យឈ្មោះ [redacted] សុគីម។

១.៣-បង្គាប់ឱ្យឈ្មោះ [redacted] ឫទ្ធី ប្រគល់រថយន្ត ០១គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្តុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944 ដែលមានបណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ឱ្យទៅឈ្មោះ រ៉េត សុគីម។

១.៤-បង្គាប់ឱ្យឈ្មោះ [redacted] ឫទ្ធី ប្រគល់ប្រាក់ចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] សុគីម។

១.៥-បង្គាប់ឱ្យឈ្មោះ [redacted] ឫទ្ធី ទទួលបន្ទុកលើប្រាក់បំណុលទាំងអស់ដែលមាន។



Scanned with CamScanner

១.៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ឈ្មោះ [redacted] ឬទ្ធី។

២-ការពន្យល់គ្រួសៗអំពីរឿងក្ដី

តាមពាក្យបណ្ដឹងចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ដើមចោទបានបញ្ជាក់ថា៖ នាងខ្ញុំ បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] ឬទ្ធី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខៈ ០៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាក្រាំងម្កាក់។ ក្នុងចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំពុំមានកូនជាមួយគ្នាទេ ប៉ុន្តែមានទ្រព្យសម្បត្តិរួម និងបំណុលរួមមាន៖

-ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

-រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944។

-បំណុលរួមនៅធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សាខាបែកចាន ដោយនាងខ្ញុំបានសងរំលោះមួយចំនួនហើយ។

ក្រោយមក យើងខ្ញុំក៏ចាប់ផ្ដើមមានភាពកកាំកកូស និងរស់នៅលែងចុះសម្រុងនឹងគ្នា ដែលនាំឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាប្ដីប្រពន្ធជាមួយគ្នាតទៅទៀត ទើបយើងខ្ញុំបានព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្តនៅសាលាឃុំម្កាក់ ដូចមានក្នុងកិច្ចសន្យាលែងលះដោយស្ម័គ្រចិត្តលេខៈ ០០៨ /២៤ កម ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

## សេចក្ដីថ្លែងការណ៍របស់គាគី

### ៣-ការអះអាងរបស់គាគី

-ដើមចោទឈ្មោះ [redacted] **សុគីម** បានថ្លែងការណ៍ថា៖ ខ្លួននៅតែរក្សាការទាមទារដូចនៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ និងដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការហេតុផល ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ទុកជាបានការដដែល។ **ដោយអះអាងថា**: ខ្លួន និងប្ដី បានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខៈ ០៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំក្រាំងម្កាក់ ក្រោយមកក៏ចាប់ផ្ដើមមានភាពកកាំកកូស និងរស់នៅលែងចុះសម្រុងនឹងគ្នា ដែលនាំឱ្យអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្ដីប្រពន្ធជាមួយគ្នាតទៅទៀត ទើបយើងខ្ញុំបានព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្តនៅសាលាឃុំម្កាក់ ដូចមាននៅក្នុងកិច្ចសន្យាលែងលះដោយស្ម័គ្រចិត្តលេខៈ០០៨/២៤ កម ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

-ក្នុងការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ ខ្លួន និងចុងចម្លើយពុំមានកូននោះទេ។

-ចំពោះទ្រព្យសម្បត្តិរួមមានដូចជា៖ ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និង រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944។ ខ្លួនទាមទារយកមកធ្វើជាកម្មសិទ្ធិផ្ដាច់មុខរបស់ខ្លួន ដូចនៅក្នុងកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្តលេខៈ០០៨/២៤ កម ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

-បំណុលរួមនៅធនាគារវឌ្ឍនៈអាស៊ីចំកាច់ (ABA) សាខាបែកចាន ចំនួន **៣១,០០០ (បីម៉ឺនមួយពាន់) ដុល្លារអាមេរិក** និងបំណុលក្រៅចំនួន **១៩,០០០ (មួយម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក** ខ្លួនបានដោះស្រាយសងទៅធនាគាររួចរាល់មួយចំនួនធំហើយ ដោយឈ្មោះ [redacted] ឬទ្ធី មិនបានជួយសងនោះទេ ហេតុនេះខ្លួនស្នើសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ឬទ្ធី ប្រគល់ប្រាក់ចំនួន **៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក** គ្រឡប់ឱ្យ



Scanned with CamScanner

ខ្លួនវិញ។ សម្រាប់សងបំណុលធនាគារ ហើយចំពោះបំណុលផ្សេងទៀតដែលខ្លួនមិនបានដឹងលឺ គឺខ្លួនមិនទទួលខុសត្រូវនោះទេ។

-ចុងចម្លើយឈ្មោះ [redacted] ឬទ្ធី បានធ្វើសេចក្ដីថ្លែងការណ៍តបថា: ការទាមទារលែងលះរបស់ដើមចោទ គឺខ្លួនឯកភាពតាមការលែងលះនេះដែរ។

-ក្នុងការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ ខ្លួន និងដើមចោទពុំមានកូន ដូចការលើកឡើងរបស់ដើមចោទមែន។

-ចំពោះទ្រព្យសម្បត្តិរួមមានដូចជា៖ ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និង រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944។ ខ្លួនយល់ព្រមប្រគល់ឱ្យដើមចោទធ្វើជាម្ចាស់កម្មសិទ្ធិផ្ដាច់មុខតាមការទាមទាររបស់ដើមចោទ និងដូចនៅក្នុងកិច្ចព្រមព្រៀងលែងលះដោយស្ម័គ្រចិត្តលេខ: ០០៨/២៤ កម ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

-បំណុលរួមនៅធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សាខាបែកចាន ចំនួន ៣១,០០០ **(បីម៉ឺនមួយពាន់) ដុល្លារអាមេរិក** និងបំណុលក្រៅចំនួន **១៥,០០០ (មួយម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក** ដែលចុងចម្លើយបានសងមួយចំនួនធំរួចហើយ ហើយចុងចម្លើយបានទាមទារឱ្យខ្លួនប្រគល់ប្រាក់ចំនួន **៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក** ត្រឡប់ឱ្យចុងចម្លើយនោះ ខ្លួនឯកភាពប្រគល់ប្រាក់ចំនួន **៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក** ទៅឱ្យចុងចម្លើយតាមការទាមទារ ហើយចំពោះបំណុលដែលមានក្រៅពីនេះខ្លួនជាអ្នកទទួលរ៉ាប់រងដោយខ្លួនឯង។

**ដើមចោទ៖ ឈ្មោះ [redacted] សុគីម បានថ្លែងការណ៍តបថា**: ខ្លួនសូមរក្សាការថ្លែងការណ៍ដូចការទាមទារខាងលើទុកជាបានការដដែល។

**ចុងចម្លើយ៖ ឈ្មោះ [redacted] ឬទ្ធី បានថ្លែងការណ៍តបថា**: ខ្លួននៅតែធ្វើការថ្លែងការណ៍ដូចខាងលើដដែល។

**<u>៤-ចំណុចមានវិវាទ៖</u>** គ្មាន។

**<u>៥-ចំណុចគ្មានវិវាទ៖</u>**

៥.១-ដើមចោទទាមទារលែងលះពីចុងចម្លើយ ចុងចម្លើយឯកភាព។

៥.២-ក្នុងការរួមរស់ជាមួយគ្នាដើមចោទ និងចុងចម្លើយពុំមានកូននោះទេ។

៥.៣-ចំពោះទ្រព្យសម្បត្តិរួមមានដូចជា៖ ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និង រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944។ ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាប្រគល់ឱ្យដើមចោទជាអ្នកមានកម្មសិទ្ធិផ្ដាច់មុខ។

៥.៤-ចុងចម្លើយបានឯកភាពប្រគល់ប្រាក់ចំនួន **៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក** មកឱ្យដើមចោទតាមការទាមទាររបស់ដើមចោទ។

***<u>៦-ភស្តុតាងដាក់ជូនតុលាការពិនិត្យរួមមាន៖</u>***

-សំបុត្រអាពាហ៍ពិពាហ៍លេខ: ០៩ សៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/២០២១ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំក្រាំងម្កាក់។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្ដាល។



Scanned with CamScanner

-បណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ចេញដោយមន្ទីរសាធារណៈការរាជធានីភ្នំពេញ។

-កិច្ចសន្យាលែងលះដោយស្ម័គ្រចិត្តលេខៈ០០៨/២៤ កម ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។

## សំអាងហេតុ

ឆ្លងតាមកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១-តាមពាក្យបណ្ដឹងដើមចោទឈ្មោះ [redacted] សុគីម ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ តុលាការអាចដោះស្រាយ និងវិនិច្ឆ័យបណ្ដឹងនេះបានដោយផ្អែកតាមមាត្រា៧ មាត្រា១០ និងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខៈ ០៩ សៀវភៅអាពាហ៍ពិពាហ៍លេខៈ ០១/២០២១ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំក្រាំងម្កាក់។ ឃើញថាដើមចោទ និងចុងចម្លើយបានបំពេញលក្ខខណ្ឌស្របតាមមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ដែលកំណត់ថា ដើមចោទ និងចុងចម្លើយ គឺជាប្ដីប្រពន្ធស្របច្បាប់។

៣-ដើមចោទបានទាមទារសុំលែងលះពីចុងចម្លើយ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា និងអស់មនោសញ្ចេតនារស់នៅជាប្ដីប្រពន្ធតទៅទៀត ហើយចុងចម្លើយក៏បានឯកភាពលែងលះជាមួយដើមចោទផងដែរ។ តុលាការពិចារណាឃើញថា ភាគីទាំងសងខាងព្រមព្រៀងលែងលះ ដោយស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។ ដូច្នេះគប្បីតុលាការសម្រេចឱ្យលែងលះគ្នាតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

៤-ក្នុងការរួមរស់ជាប្ដីប្រពន្ធ ដើមចោទ និងចុងចម្លើយពុំមានកូនទេ។

៥-ចំពោះទ្រព្យសម្បត្តិរួមមានដូចជា៖ ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និង រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944។ ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាប្រគល់ឱ្យដើមចោទជាអ្នកមានកម្មសិទ្ធិផ្ដាច់មុខ។ ដូច្នេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៦-ចុងចម្លើយបានឯកភាពប្រគល់ប្រាក់ចំនួន ៥០,០០០ (ប្រាំម៉ឺន) **ដុល្លារអាមេរិក** មកឱ្យដើមចោទតាមការទាមទាររបស់ដើមចោទ។ ដូច្នេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៧-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ស្របតាមមាត្រា ៦៤ កថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១-លែងលះដើមចោទឈ្មោះ[redacted]សុគីម និងចុងចម្លើយឈ្មោះ[redacted]ឫទ្ធី ។

២-ទ្រព្យសម្បត្តិរួមមានដូចជា៖ ផ្ទះល្វែងលេខ C5 ស្ថិតនៅផ្លូវបេតុង ភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០៨០៧០៦-០៤៤៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និង រថយន្ត ០១ (មួយ) គ្រឿង ម៉ាក TOYOTA PRIUS ពណ៌ប្រផេះ (កណ្ដុរប្រម៉េះ) ផលិតឆ្នាំ២០០៧ ពាក់ផ្លាកលេខ ភ្នំពេញ 2AP-9944 ប្រគល់ឱ្យដើមចោទឈ្មោះ[redacted]សុគីម ជាម្ចាស់កម្មសិទ្ធិ។

៣-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]ឫទ្ធី ប្រគល់ប្រាក់ចំនួន ៥០,០០០ (ប្រាំម៉ឺន) **ដុល្លារអាមេរិក** ទៅឱ្យដើមចោទឈ្មោះ[redacted]សុគីម។

៤-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ដើមចោទ ។



Scanned with CamScanner

-សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤។ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

កណ្តាល, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

កណ្តាល, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner